Khmer
[DOH-7155]

តើបាក់តេរី Staphylococcus Aureus ដែលសាុំនិងអង់ទីបីយ៉ូទិក Methicillin (MRSA)ជាអ្វី?
What Is Methicillin Resistant Staphylococcus Aureus (MRSA)?

ស្តាហ្វីឡូកុកកឺស អូរឺស (Staphylococcus aureus [ឬ staph]) គឺជាបាក់តេរីដែលមាននៅលើស្បែកនិង ក្នុងច្រមុះរបស់មនុស្ស។ ជាទូទៅ ស្តាហ្វ (staph) មិនបង្កឲ្យមានគ្រោះថ្នាក់ទេ ប៉ុន្តែជួនកាលពួកវាអាចបណ្តាលឲ្យមានការបង្ករោគនិងជម្ងឺធ្ងន់ធ្ងរ។

អំបូរនៃមេរោគ staph បានសាុំជាមួយនឹងពពួកអង់ទីបីយ៉ូទិក methicillin និង អង់ទីបីយ៉ូទិកផ្សេងៗទៀត ដែលត្រូវបានគេប្រើក្នុងអតីតកាលសំរាប់ព្យាបាលរោគ ។ ការបង្ករោគបណ្តាលមកពី methicillin-resistant Staphylococcus aureus (MRSA) ពិបាកក្នុងការព្យាបាលដោយសារអង់ទីបីយ៉ូទិកភាគច្រើន នឹងមិនអាចសំលាប់បាក់តេរីទាំងនេះបានទេ ។

តើលោកអ្នកឆ្លង MRSA យ៉ាងដូចម្តេច ?
លោកអ្នកអាចឆ្លងមេរោគMRSA នៅក្នុងសហគមន៍ក៏ដូចជានៅក្នុងមន្ទីរពេទ្យឬកន្លែងថែទាំសុខភាពផ្សេងទៀត។

MRSA និងបាក់តេរី staph ផ្សេងទៀត អាចបណ្តាលឲ្យមានការឆ្លងចូលទៅក្នុងខ្លួន តាមរយៈស្បែកដាច់រលាត់ ឬ ចូលទៅក្នុងចរន្តឈាម ។ មនុស្សដែលមានបញ្ហាសុខភាពដូចជាទឹកនោមផ្អែម ឬ ប្រព័ន្ធការពាររោគចុះខ្សោយ ឬ អ្នកមានស្បែកដាច់រលាត់ដោយសារដំបៅ/របួស, ការវះកាត់ថ្មីៗ ឬ ជម្ងឺសើស្បែក ងាយឆ្លងមេរោគ staph ជាងអ្នកផ្សេងៗទៀត ។

MRSA អាចបណ្តាលឲ្យកើត ៖

- ជម្ងឺឆ្លងលើស្បែកដូចជាបូសទ្រនិច និងពងបែក (ពងបែកនៅសាលា)
- ជម្ងឺឆ្លងក្រោមស្បែក (រលាកកោសិកា)
- ជម្ងឺធ្ងន់ធ្ងរនៅឆ្អឹង, ឈាម, សួត និង ផ្នែកផ្សេងៗទៀតនៃរាងកាយ ។

តើលោកអ្នកដឹងយ៉ាងដូចម្តេច បើសិនលោកអ្នកមានការបង្ករោគដោយ MRSA ?
វេជ្ជបណ្ឌិតនឹងបូមយកសំណាកគំរូ (swabs or samples) នៃបូសទ្រនិច, ដំបៅ ឬ ផ្នែកផ្សេងៗទៀតនៃការឆ្លងទៅពិនិត្យ ឬ ធ្វើតេស្តនៅមន្ទីរពិសោធន៍ ។

តើគេព្យាបាលជម្ងឺឆ្លងដោយ MRSA យ៉ាងដូចម្តេច ?
ជម្ងឺ MRSA អាចត្រូវបានព្យាបាលជាមួយអង់ទីបីយ៉ូទិកពិសេស ។ ការព្យាបាលផ្សេងៗទៀតរួមទាំងការរុំរបួស, ការវះកាត់ ដោយយោងទៅតាមប្រភេទនៃការបង្ករោគ ។ គ្រូពេទ្យរបស់លោកអ្នកនឹងផ្តល់ដំបូន្មានលើការព្យាបាលប្រសើរបំផុត ចំពោះការឆ្លងរបស់លោកអ្នក ។

តើជម្ងឺ MRSA ឆ្លងរាលដាលយ៉ាងដូចម្តេច ?

MRSA អាចឆ្លងរាលដាលតាមរយៈ:

- ការប៉ះឬច្របាច់កន្លែងមានរោគនៅលើរាងកាយដូចជាបូសទ្រនិច ឬ ដំបៅ
- ប្រើកន្សែងប្រឡាក់, សំលៀកបំពាក់ ឬ ស្រោមពួកដែលបានប្រើដោយជនណាម្នាក់ដែលមានរោគ MRSA ។
- ប្រើប្រាស់គ្រឿងសំអាងដែលបានប្រើដោយជនណាម្នាក់ដែលមានរោគឆ្លង MRSA ។
- មិនបានលាងដៃឲ្យបានស្អាត។

តើលោកអ្នកធ្វើដូចម្តេចដើម្បីការពារការឆ្លងរាលដាលនៃ MRSA ?

លាងដៃរបស់លោកអ្នក

ការលាងដៃគឺជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីការពារការឆ្លងរាលដាលនៃ MRSA ។

លាងដៃរបស់លោកអ្នក

- មុននិងក្រោយពេលប៉ះពាល់ ឬ រុំកន្លែងដែលមានរោគ
- ក្រោយចេញពីបង្គន់
- ក្រោយពេលជូតសំបោររួច
- មុនពេលរៀបចំ ឬ បរិភោគអាហារ
- មុនពេលប៉ះពាល់ ឬ ពរទារកទើបកើត
- ក្រោយពេលប៉ះ ឬ កាន់សំលៀកបំពាក់ ឬ កំរាលពូក ស្រោមខ្នើយដែលប្រឡាក់

តើខ្ញុំគួរលាងដៃយ៉ាងដូចម្តេច?

លាងដៃទាំងមូលរបស់លោកអ្នកឲ្យស្អាតត្រឹមត្រូវជាមួយសាប៊ូនិងទឹកម៉ាស៊ីន ។ ជូតដៃរបស់លោកអ្នកឲ្យបានស្ងួតស្អាតល្អ បន្ទាប់ពីលាងរួច។

គ្រប ឬ រុំបូសទ្រនិច និង ស្បែកដែលមានការបង្ករោគផ្សេងៗទៀត

ត្រូវគ្រប ឬ រុំបូសទ្រនិច ឬ ស្បែកដែលមានការបង្ករោគផ្សេងៗទៀតដោយក្រណាត់មិនជ្រាបទឹកនៅពេលថ្ងៃ ។ ក្មេងណាម្នាក់ដែលមានពងបែករលាក (ពងតូចៗ ឬ បន្ទះ, ពងបែកដែលមានក្រមរពណ៌រាងលឿងនៅលើស្បែក បណ្តាលមកពីបាក់តេរី staphylococcus ឬ streptococcus) មិនគួរទៅសាលារៀន ឬ ទារកដ្ឋាន រហូតដល់មានការព្យាបាលពេញមួយថ្ងៃសិន។

មិនត្រូវប្រើរួមគ្នានូវ:

- កន្សែង, សំលៀកបំពាក់ឬកំរាលពូកដែលប្រឡាក់។ បើសិនដេកគ្រែជាមួយអ្នកណាម្នាក់នោះ ត្រូវរុំ ឬ គ្របរបួស ឬ ដំបៅពេញមួយយប់តែម្តង ។
- គ្រឿងសំអិតសំអាងមួយចំនួនដូចជា : កន្ត្រៃកាត់ក្រចក, ចន្លាស/តម្បៀត, ប្រដាប់កោរ នឹង ច្រាសដុសធ្មេញ។

ត្រូវបោកគក់កន្សែង, សំលៀកបំពាក់ កំរាលពូកនិងវត្ថុផ្សេងៗទៀត ដែលអាចមានខ្ទុះឬ MRSA ដោយប្រើម៉ាស៊ីនបោកគក់ ។ ការប្រើសីតុណ្ហភាពពិសេសសំរាប់ការបោកគក់នេះ គឺមិនចាំបាច់ឡើយ ។ ត្រូវសំងួតសំលៀកបំពាក់ កំរាលពូកនិងស្រោមខ្នើយ ដោយពន្លឺព្រះអាទិត្យបើអាចធ្វើទៅបាន ពីព្រោះកំដៅថ្ងៃអាចសំលាប់ បាក់តេរីបាន។ រាល់សំភារៈបរិភោគនិងចានអាចលាងទុកដាក់តាមធម្មតាបាន។

ព័ត៌មានបន្ថែម - ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

1300 066 055

www.health.nsw.gov.au